00365769

D164/3/4

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ២៥) |
| **ភាគីដាក់ឯកសារ:** | សហមេធាវីរបស់លោក អៀង សារី |
| **ដាក់ជូន:** | អង្គបុរេជំនុំជម្រះ |
| **ភាសាដើម:** | អង់គ្លេស |
| **កាលបរិច្ឆេទឯកសារ:** | ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៩ |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 08 / 2009
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

<u>**ចំណាត់ថ្នាក់ឯកសារ**</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 25 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

---

**សេចក្តីឆ្លើយតបរបស់លោក អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធ សំណើរួមរបស់មេធាវីការពារក្តី សុំអោយបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> |
|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គបុរេជំនុំជម្រះ** |
| លោក អាង ឧត្តម | ចៅក្រម ប្រាក់ គឹមសាន |
| លោក Michael G. KARNAVAS | ចៅក្រម ន័យ ផុល |
| | ចៅក្រម ហួត វុទ្ធី |
| | ចៅក្រម Katinka LAHUIS |

00365770



ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមទៅតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត[1] និងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[2] សូមដាក់សេចក្តីឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា (“ចម្លើយតបរួមរបស់ កសព”) ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធ សំណើរួមរបស់មេធាវីការពារក្តីសុំអោយបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម SMD (“បណ្តឹងឧទ្ធរណ៍”)។ ដោយត្រូវបានដាក់ជំនួសអោយអំណះអំណាងផ្ទាល់មាត់ដែលមេធាវីការពារក្តី បានស្នើសុំដើម្បីអោយមានការប្រជុំពិភាក្សាដោយមានតម្លាភាព និងបើកចំហរ សំណើឆ្លើយតបនេះ គឺធ្វើឡើងទៅតាមមូលហេតុដូចតទៅនេះ៖ ក. កសព ទទួលស្គាល់ភាពខុសច្បាប់ដែលមានជាប់មកជាមួយរបស់ កសចស ដែលគ្រាន់តែស៊ើបសួររហូតទាល់តែខ្លួនស្វែងរកឃើញនូវភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ ប៉ុន្តែវាមិនត្រឹមត្រូវដោយ កសព ធ្វើការចង្អុលបង្ហាញលក្ខណៈឡើងវិញនូវការយល់ឃើញដែលជាក់ស្តែង និងច្បាស់លាស់នៅក្នុងវិធីមួយដែលស្រុះស្រួល និងទន់ភ្លន់[3]។ ខ. អង្គបុរេជំនុំជម្រះ <u>ត្រូវតែ</u>ដោះស្រាយនូវអ្វីដែល កសចស ថ្លែង (ហើយជាក់ស្តែងនឹងធ្វើអោយមានការខូចខាតដល់គ្រប់ជនត្រូវចោទទាំងអស់) ជាជាងតាមការបង្វិលរបស់ កសព នូវអ្វីដែលខ្លួនចង់បានពី កសចស បានថ្លែង។ គ. កសព មើលរំលងការរំលោភបំពានសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយដោយធ្វើដូច្នេះ ជាក់ស្តែងវាជាការលើកទឹកចិត្តដល់ កសចស អោយធ្វើសកម្មភាពលះបង់ចោលដោយធ្វេសប្រហែស គឺបានត្រឹមតែបំភ្លេចនូវកាតព្វកិច្ចរបស់ខ្លួនដើម្បីស៊ើបសួរជំនួសអោយជនត្រូវចោទ។ ដោយសារសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ក្នុងការបដិសេធសំណើរបស់មេធាវីការពារក្តី សុំអោយមានសវនាការដេញដោលផ្ទាល់មាត់ (និងអ្វីដែលទំនងជាករណីដូចគ្នាសម្រាប់គ្រប់សំណើសុំបែបនេះនាពេលអនាគត) ហើយនិងការកម្រិតពេលវេលាកំណត់ដ៏រឹតត្បិតបំផុតមួយផ្តល់អោយមេធាវីការពារក្តី ដើម្បីធ្វើការឆ្លើយតប សេចក្តីឆ្លើយតបនេះជាដំបូងនឹងដោះស្រាយនូវការសំអាងហេតុទាំងនេះ ដែលខ្លួនយល់

[1] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក អវតក/០១/២០០៧/វ៉.៤ ចុះថ្ងៃទី ៥ មិថុនា ២០០៩ ។

[2] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ២៥) សេចក្តីសម្រេចលើ “សំណើសុំអោយមានសវនាការដេញដោលផ្ទាល់មាត់” ទៅលើបណ្តឹងឧទ្ធរណ៍លេខ អបជ ២៤ និង ២៥ ចុះថ្ងៃទី ២០ សីហា ២០០៩ (“សេចក្តីសម្រេច”)។

[3] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ២៥) ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំអោយបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដាក់បន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ ចុះថ្ងៃទី ១០ សីហា ២០០៩ (“ចម្លើយតបរួមរបស់ កសព”)។

00365772



ឃើញថា ជាការគួរអោយបារម្ភ នៅមុនពេលធ្វើការឆ្លើយតបដោយមាំទាំទៅនឹងអំណះអំណាងនានាដែលលើកឡើងដោយ សហព្រះរាជអាជ្ញា នៅក្នុងចម្លើយតបរួមរបស់ខ្លួន ។ ដោយចូលរួម និងទទួលយកនូវបណ្តឹងឧទ្ធរណ៍រួមគ្នារបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេច[4] មេធាវីការពារក្តីបានកម្រិតការឆ្លើយតបរបស់ខ្លួន[5]តែត្រឹមតែសេចក្តីសន្និដ្ឋានបន្ថែមទៅលើ ក. អ្វីដែលសន្មតថាជា "គោលការណ៍នៃភាពគ្រប់គ្រាន់" ដែលសំអាងឡើងដោយ កសចស[6] និង ខ. ការសំអាងទៅលើ សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលការជំនុំជម្រះដោយមិនពន្យារពេលហួសហេតុ ដែលជាវិធីមួយនៃការបដិសេធសិទ្ធិរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[7]។ សេចក្តីឆ្លើយតបនេះ នឹងកម្រិតត្រឹមតែអំណះអំណាងនានារបស់ កសព តែទៅលើបញ្ហាទាំងពីរនេះ។

## I. សេចក្តីសង្ខេបទាក់ទងនឹងការបដិសេធរបស់អង្គបុរេជំនុំជម្រះមិនផ្តល់អោយមានសវនាការដោយផ្ទាល់មាត់

១. មេធាវីការពារក្តីនឹងបង្ហាញថា៖ ការបដិសេធមិនអោយមានសវនាការដេញដោលផ្ទាល់មាត់មួយទៅលើបណ្តឹងឧទ្ធរណ៍នេះដោយអង្គបុរេជំនុំជម្រះ ដែលស្នើសុំដោយមេធាវីការពារក្តីដោយឈរលើមូលដ្ឋានថា គ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងការបដិសេធសំណើសុំអោយបំពេញកិច្ចស៊ើបសួរ "ខណៈដែលជាវិធានទូទៅ [ដែលនឹងត្រូវសម្រេច] ... ឈរលើមូលដ្ឋានត្រឹមតែសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ[8]" នឹងបង្ហាញនូវការយល់ឃើញដែលមានកំហុស និងមិន

---

[4] *រឿងក្តី អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ២៤) បណ្តឹងឧទ្ធរណ៍រួមរបស់មេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួមនៅថ្ងៃទី ១៩ មិថុនា ឆ្នាំ ២០០៩ ចុះថ្ងៃទី ២៤ កក្កដា ២០០៩ ។

[5] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ២៥) បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរួមរបស់មេធាវីការពារក្តី ស្នើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាង ដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម SMD ចុះថ្ងៃទី ២៤ កក្កដា ២០០៩ ។

[6] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចលើសំណើសុំអោយបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម SMD ចុះថ្ងៃទី ១៩ មិថុនា ២០០៩ កថាខណ្ឌ ២៨-២១ ("ដីកាសម្រេចរបស់ កសចស")។

[7] *ដូចយោងខាងលើ* កថាខណ្ឌ ២៩-៣៤ ។

[8] សេចក្តីសម្រេច កថាខណ្ឌ ៥ ។

00365773



សមរម្យទៅលើគោលបំណង និង តួនាទីរបស់សវនាការដេញដោលផ្ទាល់មាត់។

២. មូលដ្ឋានសម្រាប់ការអះអាងនេះគឺ គោលការណ៍ដែលគេសន្មតនៃភាពសម្ងាត់ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៦ ("វិធាន")។ ប៉ុន្តែ ដូចដែលបានពន្យល់យ៉ាងច្រើនកាលពីមុនដោយមេធាវីការពារក្តី វិធាននេះ <u>មិន</u>បណ្តាលអោយមានជារនាំងការពារនូវភាពសម្ងាត់នៃកិច្ចស៊ើបសួរទាំងមូលនោះទេ[9]។ ខណៈដែលសំណើសុំអោយស្តាប់ចម្លើយនូវសាក្សីជាក់លាក់មួយចំនួនអាចជាការសម្ងាត់ សំណើសុំអោយបំពេញកិច្ចស៊ើបសួរអំពីថា តើតម្រូវអោយតម្រុយមួយចំនួនត្រូវតែត្រួតពិនិត្យដោយ កសចស ដែរឬទេ ករណីដូចជាបណ្តឹងឧទ្ធរណ៍ឥឡូវនេះ ដោយមិនយោងទៅលើខ្លឹមសារនៃតម្រុយទាំងនេះ អាចត្រូវបានពិភាក្សាជាសាធារណៈ ។ តាមពិត រឿងនេះវាត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ ដែលស្តែងឡើងតាមរយៈការចេញសេចក្តីសម្រេចជាសាធារណៈ[10]។ ហេតុដូច្នេះ ផ្នែកខ្លះនៃការស៊ើបសួរអាច ហើយមេធាវីការពារក្តីសូមស្នើថា ជាសាធារណៈ[11]។

៣. ជាការគួរអោយចាប់អារម្មណ៍ ករណីនេះក៏ជាការទទួលស្គាល់ផងដែរដោយ កសចស ថ្មីបើធ្វើឡើងដោយគ្មានឆន្ទះ និងបន្ទាប់ពីការគាបសង្កត់ពីខាងក្រៅដ៏លើសលប់ ដែលធ្វើសន្និសីទកាសែតស្តីពីសកម្មភាពរបស់ខ្លួន និងការបង្ហាញចេញជាសាធារណៈនូវឯកសារនានា[12]។ ប៉ុន្តែ ដោយបដិសេធនូវបណ្តឹងឧទ្ធរណ៍ពីលើកមុនរបស់មេធាវីការពារក្តី ទាក់ទងនឹងការចោទប្រកាន់រំលោភបំពានការ

---

[9] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៨) បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ និងសំណើសុំកំណត់កាលបរិច្ឆេទឆាប់រហ័សសម្រាប់ដាក់ឯកសារ និងសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី ១០ មីនា ២០០៩។

[10] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៨) សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ស្តីពីការសម្ងាត់នៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១៣ កក្កដា ២០០៩ ។

[11] *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ២៥) សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាសម្រេចស្តីពីការសម្ងាត់របស់ កសចស ចុះថ្ងៃទី ២៧ មីនា ២០០៩ ។ *សូមមើលផងដែរ* សេចក្តី ថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល ទាក់ទងនឹងការរឹតត្បិតទៅបញ្ហាតម្លាភាពដែលកើតចេញពីដីកាសម្រេចរបស់ កសចស ស្តីពីការសម្ងាត់នៃកិច្ចស៊ើបសួរ ធ្វើនៅភ្នំពេញ ថ្ងៃទី ៦ មីនា ២០០៩ ។

[12] *សូមមើល* សេចក្តីថ្លែងការណ៍ព័ត៌មានរបស់ កសចស ធ្វើនៅភ្នំពេញ ថ្ងៃទី ៣ មីនា ២០០៩ ដែលសហចៅក្រមស៊ើបអង្កេតលាតត្រដាងថា "សហចៅក្រមស៊ើបអង្កេតនឹងធ្វើការផ្សព្វផ្សាយអោយបានកាន់តែច្រើនជាងមុនអំពីសកម្មភាពនានារបស់ខ្លួន និងធ្វើការបោះឯកសារដែលទាក់ទងនឹងកិច្ចស៊ើបសួរក្នុងចំនួនច្រើនជាងមុនផងដែរ"។

00365774



សម្ងាត់[13] គួរអោយសោកស្តាយ អង្គបុរេជំនុំជម្រះ បានខកខានមិនក្តាប់យកនូវឱកាសដើម្បីធ្វើអោយច្បាស់លាស់នូវលក្ខណៈ និងវិសាលភាពនៃគោលការណ៍នេះ។

៤. ភាពសម្ងាត់ និងសវនាការដេញដោលផ្ទាល់មាត់គឺមិនមានលក្ខណៈដាច់ខាតដូចគ្នានោះទេ។ សន្មត ដោយ *អះអាង*(*arguendo*)ថា គោលការណ៍នៃ "*ភាពសម្ងាត់*" អនុញ្ញាតថា សវនាការដេញដោលផ្ទាល់មាត់ត្រូវជាការសម្ងាត់ ក្រៅតែពីកង្វះនូវចំណូលចិត្ត គ្មានអ្វីនឹងមករារាំងអង្គបុរេជំនុំជម្រះ មិនអោយបើកសវនាការដេញដោលផ្ទាល់មាត់ក្នុងការប្រជុំជាអសាធារណៈនោះទេ។ សវនាការបែបនេះគឺជាការអនុវត្តជាទូទៅនៅតុលាការជាតិ និងតុលាការអន្តរជាតិនានា។

៥. ក្នុងករណីជាក់ស្តែងនេះ សវនាការដេញដោលផ្ទាល់មាត់ ទោះជាសាធារណៈ ឬ អសាធារណៈក៏ដោយ នឹងផ្តល់អោយគូភាគីនូវពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើផែនការ និងត្រៀមរៀបចំអោយបានសមរម្យ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចកាលពីថ្ងៃព្រហស្បតិ៍ ទី២០ សីហា ២០០៩ ដោយគ្មានការព្រមានជាមុន តម្រូវអោយមេធាវីការពារក្តីដាក់ឯកសារសេចក្តីឆ្លើយតបជាលាយលក្ខណ៍អក្សរ ទាំងជាភាសាអង់គ្លេស និងភាសាខ្មែរត្រឹមថ្ងៃច័ន្ទ ទី២៤ សីហា ២០០៩។ វាគ្មានការចាំបាច់សម្រាប់ការកំណត់ថេរវេលាសម្រាប់ដាក់ឯកសារយ៉ាងបន្ទាន់បែបនេះទេ ដែលវាមានរយៈពេលខ្លីជាងឆ្ងាយណាស់ពីថេរៈវេលាកំណត់ដែលគេអនុវត្តនៅតុលាការ[14]ផ្សេងទៀត នៅពេលពេលដែលអង្គបុរេជំនុំជម្រះជាញឹកញាប់ចំណាយពេលរាប់សិបខែដើម្បីចេញសេចក្តីសម្រេចរបស់ខ្លួន[15]។

---

[13] យោងទៅសេចក្តីយោងទី ១០ ។

[14] *សូមមើល ជាឧទាហរណ៍* វិធាន ១២៦ ស្ទួន នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") ដែលចែងថា "សេចក្តីឆ្លើយតបនឹងចម្លើយតប បើសិនជាមាន ត្រូវដាក់ឯកសារក្នុងរយៈ ៧ថ្ងៃនៃថ្ងៃដាក់ឯកសារចម្លើយតបនោះ ដោយទុកការអនុញ្ញាតទៅអោយអង្គជំនុំជម្រះពាក់ព័ន្ធ" ។ បន្ថែមពីលើនេះ គួរកត់សម្គាល់ផងដែរថា នៅតុលាការ ICTY ថ្ងៃទទួលការជូនដំណឹងគឺមិនត្រូវបានគេរាប់បញ្ចូលនៅក្នុងការគណនារយៈពេលកំណត់ ដែលនេះមានន័យថា វាមានចំនួនសរុបស្មើនឹង ៨ថ្ងៃ បើប្រៀបធៀបនឹងប្រព័ន្ធនៅ អវតក ។

[15] ដោយហេតុជាករណីអនុវត្តជាក់ស្តែង ចំនួនកំណត់ ៥ថ្ងៃសម្រាប់ការដាក់សេចក្តីឆ្លើយតបក៏មិនអាចទៅរួចដើម្បីស្នើសុំអោយពន្យារពេលបន្ថែមក្រោមវិធាន ៣៩ ។ វាជាការគួរអោយឆ្ងល់ខ្លាំងបំផុតដែលសំណើសុំអោយមានការសុំពន្យារពេលបែបនេះ ដែលនឹងមានភាពសមហេតុផល និងត្រូវដាក់ឯកសារទាំងភាសាអង់គ្លេស និងភាសាខ្មែរ ក្នុងរយៈពេលកំណត់ ៥ថ្ងៃ នឹងត្រូវសម្រេចដោយអង្គបុរេជំនុំជម្រះនៅក្នុងពេលនោះ។

## II. អំណះអំណាងទាក់ទងនឹងចម្លើយតបរបស់ កសព

### ក. កសព មិនអាចចង្អុលបង្ហាញលក្ខណៈខ្សោយវិញនូវការអះអាងរបស់ កសចស ដែលច្បាស់លាស់ និងជាក់ស្តែងថា កសចស ត្រូវតែស៊ើបសួរទាល់តែមានភស្តុតាងគ្រប់គ្រាន់ដើម្បីសម្រេចចោទប្រកាន់

៦. ដីកាសម្រេចរបស់ កសចស អះអាងថា "គោលការណ៍គ្រប់គ្រាន់នៃភស្តុតាងមានប្រៀបលើគោលការណ៍មានភស្តុតាងទាំងអស់។ កិច្ចស៊ើបសួរអាចបញ្ចប់បាននៅពេលដែលចៅក្រមស៊ើបអង្កេតសំដែងការជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនជាប់ចោទ"[16]។ កសព ទទួលស្គាល់ថា គោលការណ៍ដែលគេអះអាងនេះគឺមិនមានមូលដ្ឋាន "ក្នុងបញ្ញត្តិច្បាប់ ឬមូលដ្ឋានផ្លូវច្បាប់ណាមួយឡើយ[17]" ហើយជាក់ស្តែងវាគឺជាការមិនត្រឹមត្រូវនោះទេ[18]។ កសព ព្យាយាមការពារនូវការច្រានចោលនូវដីកាសម្រេចរបស់ កសចស ដែលឈរលើមូលដ្ឋាននេះ ប៉ុន្តែយោងទៅលើបរិបទដែលអះអាងនៃសេចក្តីថ្លែងនៃគោលការណ៍[19]នេះ ហើយសន្និដ្ឋានថា "បន្ទាប់ពីការធ្វើការពិចារណាគ្រប់ជ្រុងជ្រោយ [...] ទោះបីជាមានការយោងទៅលើគោលការណ៍ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាងដែលនៅក្នុងដីកាសម្រេចនេះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត បានយល់ឃើញដោយត្រឹមត្រូវអំពីលក្ខណៈនៃកាតព្វកិច្ចនានារបស់ខ្លួន"[20]។ គ្មានអ្វីគួរអោយចាប់អារម្មណ៍ការប៉ុនប៉ងរបស់ កសព ដើម្បីចង្អុលបង្ហាញលក្ខណៈនៃខ្លឹមសារ និងចេតនាច្បាស់លាស់របស់ កសចស គឺគ្មានខ្លឹមសារ និងគ្មានទាក់ទងអ្វីទាំងអស់។

៧. សម្រាប់ពេលមួយនោះ កសចស មានភាពស្រពេចស្រពិលក្នុងការពន្យល់ថានូវជំហររបស់ខ្លួនមកលើកាតព្វកិច្ចស៊ើបសួររបស់ខ្លួនថា៖ កសចស ស៊ើបសួររហូតដល់មានភស្តុតាងគ្រប់គ្រាន់ដើម្បីសម្រេចចោទប្រកាន់ ហើយបន្ទាប់មកបិទការស៊ើបសួរ[21]។ ដោយការពន្លាតដែលសមហេតុផល និងច្បាស់លាស់ កសចស អះអាងថា ខ្លួននឹងអាចបដិសេធសំណើសុំកិច្ចស៊ើបសួរណាដែលដាក់ធ្វើបន្ទាប់ពីពេលនេះ ខណៈដែលកិច្ចស៊ើបសួរអាចនឹងត្រូវបានបញ្ចប់នោះ។ នេះគឺជារបៀបមិនត្រឹម

---

[16] ដីកាសម្រេចរបស់ កសចស កថាខណ្ឌ ៦ ។ គូសបញ្ជាក់បន្ថែម ។

[17] ចម្លើយតបរួមរបស់ កសព កថាខណ្ឌ ២៧ ។

[18] *ដូចយោងខាងលើ* កថាខណ្ឌ កថាខណ្ឌ ២៨ ។

[19] *ដូចយោងខាងលើ* ។

[20] *ដូចយោងខាងលើ* កថាខណ្ឌ ៣២ ។

[21] គូសបញ្ជាក់បន្ថែម ។

00365776



ត្រូវទាំងស្រុងនៃការបំពេញកិច្ចស៊ើបសួរដោយតុលាការមួយដែលឥតលំអៀង។

៨. ការយកជាសំអាងរបស់ កសព ទៅលើអំណះអំណាងរបស់ កសចស ដែលថា៖ (១) វាត្រូវបានដាក់បញ្ចូលជាលក្ខណៈប្រព័ន្ធទៅក្នុងសំណុំរឿងនូវឯកសារណាមួយដែលអាចបញ្ជាក់ការពិត ទោះបីជាភស្តុតាងដាក់បន្ទុក ឬ ដោះបន្ទុក ហើយ (២) មេធាវីការពារក្តីអាចជូនដំណឹងមក កសចស[22] អំពីឯកសារភស្តុតាងទាំងនោះបាន ចំណុចទាំងនេះគឺមិនគាំទ្រនូវការចង្អុលបង្ហាញលក្ខណៈរបស់ កសព ទៅលើគោលការណ៍នៃភាពគ្រប់គ្រាន់របស់ កសចស ឡើយ។ ជាក់ស្តែង វាគ្រាន់តែចង្អុលបង្ហាញថា កសចស កំពុងរង់ចាំភស្តុតាងដែលលេចចេញដោយឯកឯងជាជាងការស្វែងរកភស្តុតាងដោយត្រូវធ្វើឡើងជាមុន និងមានលក្ខណៈជាប្រព័ន្ធ។ វាក៏ចង្អុលផងដែរថា កសចស កំពុងផ្ទេរដោយមិនត្រឹមត្រូវនូវបន្ទុកនៃការស្វែងរកភស្តុតាងដោះបន្ទុក មកលើមេធាវីការពារក្តី ខណៈដែលខ្លួនព្រមានជាញយដងដល់មេធាវីការពារក្តី ចំពោះការបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង[23]។

៩. ធម្មតា ដីការបស់ កសចស ទំនងជាចង្អុលបង្ហាញថា កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២ ដែលកំពុងត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបអង្កេតជនជាតិបារាំងម្នាក់ និងចៅក្រមជនជាតិខ្មែរម្នាក់ ដែលត្រូវបានបណ្តុះបណ្តាលតាមប្រព័ន្ធច្បាប់ស៊ីវិលឡូរបស់បារាំង ជាក់ស្តែងកិច្ចស៊ើបសួរនេះកំពុងត្រូវបានគេធ្វើឡើងតាមលំនាំប្រព័ន្ធច្បាប់ខំម៉ុនឡូ ឬ ក៏ហាក់ដូចជាថា ចៅក្រមស៊ើបអង្កេតទាំងនេះ គឺជាព្រះរាជអាជ្ញាមកពីប្រព័ន្ធច្បាប់ខំម៉ុនឡូ ដែលវាផ្ទុយទៅនឹងប្រព័ន្ធច្បាប់ប្រពៃណីស៊ីវិលឡូដែលកំពុងមានអានុភាពអនុវត្តនៅចំពោះមុខ អវតក ។ ការរំលោភបំពានដែលមានជាប់មកជាមួយមកលើសិទ្ធិរបស់លោក អៀង សារី នៅក្នុងការប្រកាន់យកវិធីសាស្ត្របែបនេះ ត្រូវតែបានប៉ះប៉ូវដោយអង្គបុរេជំនុំជម្រះ និងតាមរយៈការចង្អុលបង្ហាញដែលសមរម្យ និងការណែនាំ

---

[22] ចម្លើយតបរួមរបស់ កសព កថាខណ្ឌ ៣០ ធ្វើការសង្ខេបនូវដីកាសម្រេច របស់ កសចស កថាខណ្ឌ ១៥ ។

[23] កសចស ពីមុនបានគូសបញ្ជាក់ថាតួនាទីមានកម្រិតរបស់គូភាគីទាក់ទងនឹងការស៊ើបសួររបស់ អវតក "នៅចំពោះមុខតុលាការនេះ អំណាចដើម្បីបំពេញកិច្ចស៊ើបសួរគឺត្រូវបានចាត់អោយទាំងស្រុងទៅសហចៅក្រមស៊ើបអង្កេតឯករាជ្យពីរនាក់ មិនមែនគូភាគីទេ។ មិនមានបទបញ្ញត្តិ ដែលអនុញ្ញាតអោយគូភាគីបំពេញកិច្ចស៊ើបសួរជំនួសអោយសហចៅក្រមស៊ើបអង្កេតឡើយ ដែលករណីនេះអាចធ្វើបាននៅក្នុងប្រព័ន្ធនីតិវិធីផ្សេងទៀត។ [...] ដូច្នេះ សមត្ថភាពនៃគូភាគីដើម្បីធ្វើអន្តរាគមន៍មានកំរិតត្រឹមការស៊ើបអង្កេតបឋមដែលចាំបាច់បំផុតសម្រាប់អោយខ្លួនអាចប្រើប្រាស់អោយមានប្រសិទ្ធិភាព នូវសិទ្ធិរបស់ពួកគេដើម្បីធ្វើសំណើសុំអោយបំពេញកិច្ចស៊ើបសួរ"។ *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស អនុស្សារណៈអន្តរការិយាល័យរបស់ កសចស មកមេធាវីការពារក្តី ចុះថ្ងៃទី ១០ មករា ២០០៨ ទំព័រ ២ ។

00365777



ដែលម៉ឹងម៉ាត់ទៅកាន់ កសចស សម្រាប់កិច្ចស៊ើបសួរដែលនៅសេសសល់ដទៃទៀត[24]។

**ខ. ដីកាសម្រេចរបស់ កសចស មិនត្រូវដាក់ស្មើគ្នានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិទទួលការជំនុំជម្រះដោយមិនពន្យារពេលហួសហេតុ ឬ មិនបានព្យាយាមការពារសិទ្ធិទាំងនេះក្នុងការបដិសេធចោលនូវសំណើសុំអោយបំពេញកិច្ចស៊ើបសួរ**

១០. ក្នុងកិច្ចប៉ុនប៉ងមួយដើម្បីធ្វើយុត្តិកម្មនូវការសំអាងហេតុដែលមិនត្រឹមត្រូវរបស់ កសចស នេះ កសព អះអាងថា ដីកាសម្រេចរបស់ កសចស "(១) ដាក់កាតព្វកិច្ចផ្សេងៗអោយអនុលោមទៅតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិទទួលការជំនុំជម្រះដោយឆាប់រហ័សដោយមិនការអូសបន្លាយដោយមិនត្រឹមត្រូវ ក្នុងភាពដែលមានសិទ្ធិស្មើគ្នា អនុវត្តកាតព្វកិច្ចនោះដោយសន្សឹមៗ និង (២) ស្វែងរកដើម្បីការពារនូវសិទ្ធិទាំងនោះដោយបដិសេធចោលនូវសំណើទាំងឡាយណាដែលមិនច្បាស់លាស់ និងមិនជាក់លាក់"[25]។ សេចក្តីថ្លែងនេះដូចជាមិនបានបញ្ជាក់នូវការបកស្រាយដ៏សមហេតុផលណាមួយទៅលើដីកាសម្រេចរបស់ កសចស ទាល់តែសោះ។

១១. កសចស អះអាងថា "សហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវដាក់កំហិតពេលវេលាជាក់លាក់មួយបើហួសពីនេះខ្លួនមុខជានឹងធ្វើអោយប៉ះពាល់ដល់ភាពយុត្តិធម៌នៃដំណើរការកាត់ក្តី" ហើយថា "ខ្លួនមានសិទ្ធិ ឬក៏អាចថាមានកាតព្វកិច្ច ទាត់ចោលនូវសំណើសុំអោយបំពេញកិច្ចស៊ើបសួររបស់ភាគីទាំងឡាយណាដែលខ្លួនវិនិច្ឆ័យឃើញថា វាមិនមានប្រយោជន៍ដល់ការបង្ហាញការពិត"[26]។ ប៉ុន្តែចំនុចនេះមិនមែនមានន័យថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិទទួលការជំនុំជម្រះដោយមិនពន្យារពេលហួសហេតុ ត្រូវដាក់អោយមានភាពស្មើគ្នាឡើយ។ ផ្ទុយទៅវិញវាបង្កប់ន័យដ៏ខ្លាំងថា កសចស កំពុងយកជាសំអាងដោយមិនត្រឹមត្រូវទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យារពេលហួសហេតុ ដើម្បីបដិសេធសំណើសុំអោយបំពេញកិច្ចស៊ើបសួរដែលមានភាពស្របច្បាប់។

---

[24] *សូមមើលជាទូទៅ រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើលើកទីបីរបស់លោក អៀង សារី ស្នើសុំអោយបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ២១ ឧសភា ២០០៩ ដែលស្នើសុំព័ត៌មានពី កសចស ស្តីពី របៀប នីតិវិធី និងវិសាលភាព នៃកិច្ចស៊ើបសួរ ។ សំណើសុំនេះត្រូវបានធ្វើជាចាំបាច់ដោយសារកង្វះព័ត៌មានស្តីពីវិធាន និង នីតិវិធីដែល កសចស ត្រូវដើរតាមនោះ ស្តីអំពីសំណុំរឿង ។

[25] ចម្លើយតបរួមរបស់ កសព កថាខណ្ឌ ៤០ ។

[26] *ដូចយោងខាងលើ* ។

00365778



១២. ដោយយ៉ាងងាយស្រួល ដីកាសម្រេចរបស់ កសចស មិនបានដោះស្រាយនូវការលះបង់សិទ្ធិជាក់លាក់ដែលចុះហត្ថលេខា និងដាក់ឯកសារជូនដោយលោក អៀង សារី ដើម្បីជួយសម្រួលដល់ការស៊ើបសួររបស់ កសចស ទៅលើ SMD ដោយមិនរំលោភបំពានសិទ្ធិរបស់គាត់ក្នុងការទទួលការជំនុំជម្រះដោយមិនពន្យារពេលហួសហេតុ[27] ។ តាមពិត សូម្បីតែក្តីកង្វល់របស់ កសចស ទៅលើរយៈពេលនៃកិច្ចស៊ើបសួរគឺមានលក្ខណៈស្របច្បាប់ ជាជាងការដោះសារដ៏ងាយមួយដើម្បីបដិសេធនូវសំណើសុំអោយបំពេញកិច្ចស៊ើបសួរដ៏មានសុពលមួយ កសព ខកខានមិនបានដោះស្រាយថា តើ លោក អៀង សារី អាចស្នើសុំដោយខ្លួនឯងអោយអនុវត្តនូវសិទ្ធិមួយជាជាងសិទ្ធិមួយទៀតដែរឬទេ។

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលដូចដែលបានលើកឡើងនៅក្នុងសេចក្តីឆ្លើយតបនេះ មេធាវីការពារសូមស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះសូមអោយ៖

ក. **ច្រានចោល** ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំអោយបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកក្នុងឃ្លាំងផ្ទុកឯកសាររួមSMD ។

ខ. **ប្រកាស** ថាគោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាងដែលទទួលយក កសចស មិនមាននៅក្នុងប្រព័ន្ធច្បាប់របស់ អវតក ឡើយ ហើយថា កសចស ត្រូវស្រាវជ្រាវជាមុនសិននូវនិងពិចារណាគ្រប់ភស្តុតាងដោះបន្ទុកទាំងអស់ នៅពេលធ្វើការវាយតម្លៃថា តើត្រូវបញ្ជូនរឿងទៅជំនុំជម្រះក្រោមមាត្រា ៦៧(១) ដែរឬទេ ។

គ. **បង្គាប់** អោយ កសចស ត្រួតពិនិត្យនូវឯកសារទាំងអស់ដែលមានផ្ទុកក្នុង SMD

ឃ. **បង្គាប់** កសចស អោយបង្កើតនូវរបាយការណ៍ពិស្តារគ្រប់គ្រាន់មួយ នូវការវិភាគរបស់ខ្លួនដើម្បីអាចអោយមេធាវីការពារក្តី ធានាថា គ្រប់កិច្ចស៊ើបសួរចាំបាច់ទាំងអស់ត្រូវបានធ្វើឡើងដើម្បីបង្ហាញអត្តសញ្ញាណនៃភស្តុតាងដោះបន្ទុកដែលមានសក្តានុពល ។ និង

ង. **បង្គាប់** អោយ កសចស ផ្តល់នូវបញ្ជីនៃតម្រុយដោះបន្ទុកដែលមានផ្ទុកក្នុង SMD ។

---

[27] បណ្តឹងឧទ្ធរណ៍កថាខណ្ឌ ១២ ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកសេចក្តីឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៤** ខែ**សីហា** ឆ្នាំ **២០០៩**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**